# ពិធីចុះហត្ថលេខាលើកិច្ចសន្យាសម្បទានស្តីពីការផ្តល់សិទ្ធិស្ថាបនា ប្រតិបត្តិការ និងផ្តល់បណ្តាញទូរស័ព្ទសាធារណៈ និងសេវា អចល័ត (PSTN)




ពិធីចុះហត្ថលេខាលើកិច្ចសន្យាសម្បទានស្តីពីការផ្តល់សិទ្ធិស្ថាបនា ប្រតិបត្តិការ និងផ្តល់បណ្តាញទូរស័ព្ទសាធារណៈ និងសេវា អចល័ត (PSTN) បានប្រារព្ធឡើងកាលពីព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ នៅទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រវាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រុមហ៊ុន វៀតតែល (កម្ពុជា) ។

នៅក្នុងពិធីនោះ ឯកឧត្តម **សូរ ឃុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានថ្លែងថា តាងនាមរាជរដ្ឋាភិបាលប្រទេសកម្ពុជា និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឯកឧត្តមមានសេចក្តីរីករាយជា អតិបរមាដែលបានចូលរួមក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាសម្បទានស្តីពីការផ្តល់សិទ្ធិ ស្ថាបនា ប្រតិបត្តិការ និងផ្តល់បណ្តាញទូរស័ព្ទសាធារណៈ និងសេវាអចល័ត (PSTN) នៅក្នុងព្រះរាជាណាចក្រកម្ពុជា រវាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រុមហ៊ុន Viettel (Cambodia) ។

ឯកឧត្តមរដ្ឋមន្ត្រី **សូរ ឃុន** បានបន្តទៀតថា ក្នុងរយៈពេលជាងមួយទសវត្សនេះ កិច្ចអភិវឌ្ឍន៍លើវិស័យទូរគមនាគមន៍ ក្នុងព្រះរាជាណាចក្រកម្ពុជា មានសន្ទុះជឿនលឿនយ៉ាងធំធេង ជាពិសេសគឺ ការផ្តល់សេវាទូរស័ព្ទចល័ត ដែលមានអ្នកប្រើប្រាស់ ទាំងអស់ចំនួន បួនលាននាក់ រហូតមកដល់ពេលនេះ ។

ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ទៀតថា ក្នុងរយៈពេលកន្លងមកនេះក្រុមហ៊ុន Viettel (Cambodia) បានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជាឱ្យធ្វើការវិនិយោគលើការស្ថាបនាខ្សែកាប្លិ៍ ការផ្តល់សេវាទូរស័ព្ទចល័ត ការផ្តល់សេវាទូរស័ព្ទតាមប្រព័ន្ធអ៊ិនធឺណិត ( VoIP) និងផ្តល់ជំនួយដល់រាជរដ្ឋាភិបាលសម្រាប់Vieo Converence

នៅក្នុងព្រះរាជាណាចក្រកម្ពុជា។




ឯកឧត្តម **សូរ ឃុន** បានបន្ថែមថា ដោយសារការផ្តល់សេវាទូរស័ព្ទចល័តមានការរីកចម្រើនជាងសេវាទូរស័ព្ទអចល័ត រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យក្រុមហ៊ុន Viettel (Cambodia) នេះធ្វើការអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ក្នុងការស្ថាបនាប្រតិបត្តិការ និងផ្តល់បណ្តាញទូរស័ព្ទសាធារណៈ និងសេវាអចល័ត (PSTN)ដើម្បីវិនិយោគទុនផ្តល់សេវានេះជូនប្រជាពលរដ្ឋនៅគ្រប់ខេត្ត-ក្រុងនានាក្នុងប្រទេសក្នុងរយៈពេល២ឆ្នាំខាងមុខនេះ។

ជាងនេះទៀត ឯកឧត្តមរដ្ឋមន្ត្រី **សូរ ឃុន** បានសង្កត់ធ្ងន់ថា បន្ទាប់ពីបានចុះកិច្ចសន្យាសម្បទានរវាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រុមហ៊ុន Viettel (VTC) ក្រសួងក៏បានចេញអាជ្ញាប័ណ្ណមួយជូនក្រុមហ៊ុន ដើម្បីអនុវត្តគម្រោងខាងលើនេះឱ្យមានប្រសិទ្ធភាពល្អស្របតាមខ្លឹមសារ និងលក្ខខ័ណ្ឌនៃកិច្ចសន្យាសម្បទាន និងខ្លឹមសារអាជ្ញាប័ណ្ណ។

ជាទីបញ្ចប់ ឯកឧត្តម **សូរ ឃុន** ក៏បានប្រសិទ្ធពរ ជូនក្រុមហ៊ុន Viettel (Cambodia) ទទួលបានជោគជ័យដ៏ធំធេងក្នុងការស្ថាបនាបណ្តាញទូរស័ព្ទសាធារណៈ និងការផ្តល់សេវាអចល័តតាមផែនការកំណត់។

លោក **ឡេវ៉ៃ ឌិកខ្វាង** នាយកគ្រប់គ្រងក្រុមហ៊ុន Viettel (Cambodia) PTE; Ltd បានមានប្រសាសន៍ថា ក្រុមហ៊ុន Viettel សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដែលបានផ្តល់អាជ្ញាប័ណ្ណឱ្យក្រុមហ៊ុនធ្វើប្រតិបត្តិការបម្រើសេវាទូរស័ព្ទទាំងពីរប្រភេទជូនអតិថិជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយក្រុមហ៊ុន Viettel នឹងខិតខំយកអស់ពីកម្លាំងកាយចិត្ត ដើម្បីបម្រើសេវា ទូរគមនាគមន៍ឱ្យកាន់តែប្រសើរឡើង ប្រកបដោយទំនុកចិត្ត និងគុណភាពខ្ពស់។